# រឿងនាងសុមនារាជកុមារី

*នាងសុមនា រាជកុមារី គឺជាព្រះរាជធីតានៃព្រះបាទបសេនទិកោសល មានព្រះនាមថា* **សុមនា** *។ ដែលបានព្រះនាមដូច្នោះ ព្រោះព្រះរាជធីតាទ្រង់បានធ្វើនូវមហាសក្ការៈហើយ ទ្រង់តាំងសេចក្តីប្រាថ្នាទុកមក ។*

*សេចក្តីពិស្តារ មានតាំងអំពីសាសនានៃព្រះសម្មាសម្ពុទ្ធវិបស្សី គឺពួកអ្នកនគរគិតគ្នាថា ពួកយើងបញ្ចប់សង្គ្រាមហើយ ពួកយើងគប្បីថ្វាយទានដល់សង្ឃមានព្រះពុទ្ធជាព្រះសាស្តារបស់យើងជាប្រមុខ ។ ដោយអ្នកនគរអាស្រ័យសេនាបតីហើយធ្វើបុណ្យតាមលំដាប់ ដូច្នេះ ក្នុងថ្ងៃមុនដំបូង ជាវារៈរបស់សេនាបតី ។ ក្នុងថ្ងៃនោះ សេនាបតីត្រៀមមហាទាន ដាក់មនុស្សយាមការពារជុំវិញ ដោយបញ្ជាថា ថ្ងៃនេះ ពួកអ្នកចូរយាមដោយប្រុងប្រយ័ត្ន គឺកុំឲ្យអ្នកណាៗ មកថ្វាយភិក្ខាឡើយ ។*

*ក្នុងថ្ងៃនោះ មានភរិយាលោកសេដ្ឋីម្នាក់អង្គុយយំផង និយាយទៅរកធីតារបស់ខ្លួនផងថា កូនស្រីម្តាយអើយ ប្រសិនបើបិតារបស់កូននៅរស់រានមានជីវិតនោះ គឺក្នុងថ្ងៃនេះ ម្តាយនឹងនិមន្តព្រះទសពលឆាន់ជាគ្រាដំបូង ។ កូនស្រីនិយាយនឹងមាតាថាបពិត្រអ្នកម៉ែ សូមអ្នកម៉ែកុំភ័យព្រួយអ្វីឡើយ កូននឹងធ្វើដោយឧបាយវិធី ដែលអាចឲ្យព្រះសង្ឃមានព្រះពុទ្ធបរមគ្រូជាប្រមុខ ឆាន់នូវភិក្ខារបស់យើងជាគ្រាដំបូង ។ ភ្លាមៗ នោះ ធីតានៃលោកសេដ្ឋី បានចាត់ចែងចង្ហាន់ដែលមិនមានទឹក គឺនិរុទកបាយាស ដាក់ចុះនៅក្នុងថាសមាស ដែលថាសមាសនោះ មានតម្លៃ ១ សែន រហូតពេញថាស ហើយទើបដាក់ទឹកដោះគោ ទឹកឃ្មុំ និង ស្ករក្រួសជាដើមលាយចូល ទើបយកថាសមួយទៀតគ្រប រួចហើយ*

យកភួងផ្កាម្លិះមករៀបចំដាក់គ្របពីលើភាជនៈនោះ ឲ្យដូចជាភាជនៈផ្កាម្លិះដូច្នោះ ៦៥ ។

លុះដល់ភត្តកាល ព្រះដ៏មានព្រះភាគស្តេចយាងព្រមដោយព្រះភិក្ខុសង្ឃ ចូលទៅកាន់ភូមិ សំដៅទៅផ្ទះសេនាបតី ។ សេដ្ឋីធីតា នាងនាំយកភាជនៈមាស ដាក់ភិក្ខាគ្របដោយផ្កាម្លិះ មានពួកនាងទាសីហែហាមចេញអំពីផ្ទះ ស្កាត់ផ្លូវព្រះដ៏មានព្រះភាគ ។ នៅក្នុងរវាងផ្លូវ ពួកអ្នកយាមរបស់សេនាបតីពោលថា នែនាង! កុំទៅផ្លូវនេះ ។ ធម្មតាអ្នកមានបុណ្យច្រើន រមែងមានពាក្យសម្តីត្រូវចិត្តអ្នកស្តាប់ នាងពោលទៅរកអ្នកយាមទាំងឡាយ ដែលចេះតែហាមហើយហាមទៀតថា លោកបង លោកតូ លោកអ៊ំ ព្រោះហេតុអ្វីបានជាមិនឲ្យពួកនាងខ្ញុំចូលទៅ ពួកអ្នកយាមពោលថា អើនាង! លោកសេនាបតី ចាត់ពួកយើងឲ្យយាមរក្សាការណ៍ ដោយបង្គាប់ថា កុំឲ្យអ្នកណាៗ នាំយកអាហារភោជនចូលមកជាដាច់ខាត ។ នាងពោលថា ក៏ពួកលោកឃើញអាហារភោជនក្នុងដៃរបស់ខ្ញុំឬ? ពួកអ្នកយាមពោលថា ឃើញតែភួងផ្កា ។ នាងសួរថា លោកសេនាបតី មិនឲ្យធ្វើសូម្បីតែការបូជា ដោយភួងផ្កាឬ? ពួកអ្នកយាមពោលថា លោកសេនាបតីអត់ហាមទេ ។ នាងពោលថា បើយ៉ាងនេះ សូមពួកលោកបើកផ្លូវទៅ ។

បានឱកាសហើយ នាងក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ទទួលនូវភួងផ្កាម្លិះនេះ ព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ទតព្រះនេត្រទៅរកអ្នកបម្រើសេនាបតីម្នាក់ ហើយត្រាស់ឲ្យទទួលភួងផ្កាម្លិះទុកតាមព្រះអង្គទៅ ។ នាងថ្វាយបង្គំព្រះបរមសាស្តាហើយ នាងតាំងសេចក្តីប្រាថ្នាថា កាលដែលខ្ញុំម្ចាស់កើតក្នុងភពតូចភពធំតទៅ សូមកុំឲ្យខ្ញុំ

ម្ចាស់ មានជីវិតរស់នៅដោយសេចក្ដីតក់ស្លុតឡើយ សូមឲ្យបានជាទីស្រឡាញ់ដូចក្ដួងផ្កាម្លិះនេះ និង សូមឲ្យមានឈ្មោះថា **សុមនា** រហូត ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា នាងចូរមានសេចក្ដីសុខចុះ ។ សេដ្ឋីធីតា ថ្វាយបង្គំហើយធ្វើប្រទក្សិណព្រះដ៏មានព្រះភាគ ក្រាបទូលលាត្រឡប់ទៅផ្ទះវិញ ។

ព្រះដ៏មានព្រះភាគស្ដេចយាងដល់ផ្ទះសេនាបតី ទ្រង់គង់ប្រថាប់លើអាសនៈដែលគេក្រាលថ្វាយ សេនាបតីកាន់យកបបរយាគូ បង្អោនចូលទៅថ្វាយ ព្រះបរមសាស្ដា ទ្រង់យកព្រះហស្ដបិទបាត្រ ។ សេនាបតីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងឡាយ គង់រៀបរយហើយ ព្រះអង្គ ។ ព្រះដ៏មានព្រះភាគត្រាស់ថា តថាគតបានបិណ្ឌបាតក្នុងរវាងផ្លូវហើយ ។ សេនាបតីលើកក្ដួងផ្កាម្លិះចេញបានឃើញបិណ្ឌបាត មធុបាយាសគ្រប់ល្មមដល់ភិក្ខុទាំងឡាយ ដួសថ្វាយតាំងពីព្រះដ៏មានព្រះភាគទៅ រីឯសេនាបតីបានថ្វាយនូវទេយ្យធម៌របស់ខ្លួន ។ ព្រះបរមសាស្ដាសោយស្រេចហើយ ទ្រង់ត្រាស់សម្ដែងនូវមង្គលកថា រួចស្ដេចយាងត្រឡប់ ។

សេនាបតីសួរថា ស្រីដែលថ្វាយបិណ្ឌបាតជាអ្នកណា? កូនស្រីលោកសេដ្ឋីទានប្រោស ។ សេនាបតីគិតថា ស្ត្រីដែលមានបញ្ញា កាលដែលមកនៅក្នុងផ្ទះរបស់យើង គឺថា សគ្គសម្បត្តិរបស់បុរសមិនមែនរកបានដោយក្រទេ គិតហើយទើបចាត់ចែងនាំនាងបានមកតាំងទុកក្នុងតំណែងជាប្រមុខ ។

សេដ្ឋីធីតា បានមកនៅផ្ទះសេនាបតីហើយ ក៏ចាប់ផ្ដើមចំណាយទ្រព្យក្នុងផ្ទះរបស់មាតា និង ក្នុងផ្ទះរបស់សេនាបតី ថ្វាយទានដល់ព្រះសម្មាសម្ពុទ្ធ បំពេញ

បុណ្យ រហូតអស់អាយុ ។ កាលដែលនាងចុតិអំពីមនុស្ស បានទៅបដិសន្ធិក្នុងទេវលោកកាមាវចរសួគ៌ ។ ក្នុងខណៈដែលនាងកើតនោះឯងមានភ្លៀងផ្កាម្លិះទូទៅពេញទេវលោក ត្រឹមក្បាលជង្គង់ ។ ពួកទេវតាទាំងឡាយគិតគ្នាថា ទេពធីតានេះកាន់យកឈ្មោះរបស់ខ្លួនដោយខ្លួនឯងមក ទើបតាំងនាមទេពធីតាថា **សុមនា** ។ សុមនាទេពធីតា ចុតិបដិសន្ធិក្នុងទេវលោក និង មនុស្សលោក រហូត ៨៩ កប្បក្នុងទីដែលនាងកើតហើយនោះៗ ភ្លៀងផ្កាម្លិះក៏ធ្លាក់មកជានិច្ច ទើបមានឈ្មោះថា សុមនា ដូចដើម ។ កាលដែលនាងមកបដិសន្ធិ ក្នុងព្រះគភ៌របស់ព្រះអគ្គមហេសីនៃព្រះបាទកោសល ក្នុងថ្ងៃនោះឯង កុមារិកា ៥០០ នាក់ ក៏បដិសន្ធិក្នុងត្រកូលនោះៗ ហើយប្រសូតចាកគភ៌ក្នុងថ្ងៃតែមួយជាមួយគ្នាទាំងអស់ ។ ក្នុងខណៈព្រះរាជធីតាប្រសូតនោះឯង ភ្លៀងផ្កាម្លិះធ្លាក់ចុះប្រមាណត្រឹមជង្គង់ ។

ព្រះរាជា ទតព្រះនេត្រឃើញព្រះធីតា ទ្រង់សប្បាយព្រះហឫទ័យក្រៃលែងដោយព្រះរាជាទ្រង់ជ្រាបថា ព្រះរាជធីតានេះ ជាអ្នកមានបុណ្យបានសាងទុកមកហើយ ធីតារបស់យើងកាន់យកឈ្មោះរបស់ខ្លួនមកដោយខ្លួនឯង ទើបទ្រង់ព្រះរាជទានព្រះនាមថា **សុមនា** ដល់ព្រះរាជធីតារបស់ព្រះអង្គ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ធីតារបស់យើងប្រាកដជាមិនកើតមកតែម្នាក់ឯងនោះឡើយ ទ្រង់ឲ្យស្វែងរកឃើញមានទារិកា ៥០០ នាក់ កើតក្នុងព្រះនគរ ទើបទ្រង់ត្រាស់ឲ្យចិញ្ចឹមទុកទាំងអស់ ហើយត្រូវនាំមកបង្ហាញដល់ធីតារបស់យើងមួយខែម្តងៗ ។

នៅពេលដែលព្រះរាជធីតា មាននូវព្រះជន្មវស្សាបាន ៧ ខួប លោកសេដ្ឋីអនាថបិណ្ឌិក បានសាងព្រះជេតពនមហាវិហារហើយស្រេច ។ កាលដែល

បានបញ្ជូនទូតទៅក្រាបទូលដល់ព្រះបរមសាស្តាហើយ  ព្រះលោកនាថជាព្រះសុគតសាស្តា មានព្រះភិក្ខុសង្ឃជាបរិវារ ស្តេចយាងចូលកាន់ក្រុងសាវត្ថី ។

អនាថបិណ្ឌិកសេដ្ឋី បានចូលទៅក្រាបទូលដល់ព្រះរាជាថាបពិត្រព្រះមហារាជដ៏ចម្រើន  ព្រះពុទ្ធដំណើរស្តេចយាងមកកាន់ទីនេះ  ជាមង្គលទាំងដល់ខ្ញុំព្រះអង្គទាំងដល់ព្រះអង្គ  ជាព្រះរាជា  សូមព្រះអង្គទ្រង់ប្រោសឲ្យព្រះនាងសុមនារាជកុមារី ព្រមដោយកុមារីដទៃជាបរិវារ ៥០០ នាក់ កាន់ក្អមទឹកនិងផ្កាកម្រងគ្រឿងក្រអូបជាដើម ទទួលដំណើរព្រះទសពល ព្រះអង្គ ។ ព្រះរាជាទ្រង់ត្រាស់ថា ល្អហើយ លោកសេដ្ឋី ហើយព្រះអង្គក៏ទ្រង់ចាត់ចែងដូច្នោះ ។ ព្រះរាជធីតា ក៏បានចូលគាល់ព្រះបរមសាសាសម្មាសម្ពុទ្ធ តាមពាក្យដែលព្រះបិតាទ្រង់ណែនាំ បានបូជាដោយផ្កាកម្រង  និងគ្រឿងក្រអូបជាដើម  ហើយប្រថាប់នៅក្នុងទីដ៏សមគួរមួយ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងព្រះធម៌ទេសនា ញុំាងព្រះធីតានិងកុមារីទាំង ៥០០ នាក់ ឲ្យតាំងនៅក្នុងសោតាបត្តិផល ។ ក្នុងរវាងផ្លូវថ្ងៃនោះ មានគ្រហស្ថបានសម្រេចសោតាបត្តិផល ២ ពាន់នាក់ ។

## នាងសុមនារាជកុមារី ទូលសួរបញ្ហានឹងព្រះមានព្រះភាគ

គ្រានោះ  នាងសុមនារាជកុមារី  មានរថ  ៥០០  និងរាជកុមារី  ៥០០  អង្គហែហមចូលទៅគាល់ព្រះដ៏មានព្រះភាគ  លុះចូលទៅដល់  ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយប្រថាប់ក្នុងទីសមគួរ ។ លុះនាងសុមនា រាជកុមារី ប្រថាប់នៅក្នុងទីសមគួរ  ។  បានទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា  បពិត្រព្រះអង្គដ៏ចម្រើនសាវ័កទាំងពីររូប  របស់ព្រះដ៏មានព្រះភាគ  ក្នុងសាសនានេះ  មានសទ្ធាស្មើគ្នា

មានសីលស្មើគ្នា មានបញ្ញាស្មើគ្នា ប៉ុន្តែមួយអង្គជាទាយក មួយអង្គមិនមែនទាយក សាវ័កទាំងនោះ ដល់បែកធ្លាយរាងកាយ ស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក បពិត្រព្រះអង្គដ៏ចម្រើន សាវ័កទាំងពីរ ដែលកើតជាទេវតានោះ តើមានសេចក្តីវិសេស មានហេតុផ្សេងគ្នាដែរឬទេ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលនាងសុមនា មានដែរ ម្នាលនាងសុមនា សាវ័កណា ជាទាយក សាវ័កនោះ ដល់កើតជាទេវតា រមែងគ្របសង្កត់ ទេវតាឯណោះ ដែលមិនមែនជាទាយក ដោយហេតុ ៥ យ៉ាង គឺ អាយុទិព្វ ១ សម្បុរទិព្វ ១ សុខទិព្វ ១ យសទិព្វ ១ អាធិបតេយ្យទិព្វ ១ ។ ម្នាលនាងសុមនា សាវ័កណា ជាទាយក សាវ័កនោះ ដល់ទៅកើតជាទេវតា រមែងគ្របសង្កត់ទេវតាឯណោះ ដែលមិនមែនជាទាយក ដោយហេតុ ៥ យ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះបើទេវតាទាំងពីរនោះ ច្យុតអំពីទេវលោកនោះ មកកើតក្នុងមនុស្សលោកនេះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលទាំងពីរនោះ ដែលកើតជាមនុស្សហើយ តើមានសេចក្តីវិសេស មានហេតុផ្សេងគ្នាដែរឬទេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលនាងសុមនា មានដែរ ម្នាលនាងសុមនា បុគ្គលណា ជាទាយក បុគ្គលនោះ ដល់កើតជាមនុស្ស រមែងគ្របសង្កត់បុគ្គលឯណោះ ដែលមិនមែនជាទាយក ដោយហេតុ ៥ យ៉ាង គឺ អាយុជារបស់មនុស្ស ១ សម្បុរជារបស់មនុស្ស ១ សុខជារបស់មនុស្ស ១ យសជារបស់មនុស្ស ១ អាធិបតេយ្យជារបស់មនុស្ស ១ ។ ម្នាលនាងសុមនា បុគ្គលណា ជាទាយក បុគ្គលនោះ ដល់មកកើតជាមនុស្ស រមែងគ្របសង្កត់បុគ្គលឯណោះ ដែលមិនមែនជាទាយក ដោយហេតុ ៥ យ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះបើអ្នកទាំងពីរនោះ ចេញចាកផ្ទះបួស បពិត្រព្រះអង្គដ៏ចម្រើន បព្វជិត

ទាំងនោះ តើមានសេចក្តីវិសេស មានហេតុផ្សេងគ្នាដែរឬទេ ។ ព្រះដ៏មានព្រះភាគ ត្រាស់ថា ម្នាលនាងសុមនា មានដែរ ម្នាលនាងសុមនា បុគ្គលណា ជាទាយក បុគ្គលនោះ លុះដល់បានបួសហើយ រមែងគ្របសង្កត់បព្វជិតឯណោះ ដែលមិនមែនជាទាយក ដោយហេតុ ៥ យ៉ាង គឺបើគេអង្វរ រមែងប្រើប្រាស់ចីវរច្រើន បើគេមិនអង្វរ ប្រើប្រាស់ចីវរតិច ១ បើគេអង្វរ រមែងបរិភោគបិណ្ឌបាតច្រើន បើគេមិនអង្វរ ក៏បរិភោគបិណ្ឌបាតតិច ១ បើគេអង្វរ រមែងប្រើប្រាស់សេនាសនៈច្រើន បើគេមិនអង្វរ ក៏ប្រើប្រាស់សេនាសនៈតិច ១ បើគេអង្វរ រមែងប្រើប្រាស់គិលានប្បច្ចយភេសជ្ជបរិក្ខារច្រើន បើគេមិនអង្វរ ក៏ប្រើប្រាស់គិលានប្បច្ចយភេសជ្ជបរិក្ខារតិច ១ ប្រសិនបើ នៅជាមួយពួកសព្រហ្មចារីណា ពួកសព្រហ្មចារីនោះ រមែងរាប់អានភិក្ខុនោះ ដោយកាយកម្ម ជាទីគាប់ចិត្តច្រើន មិនជាទីគាប់ចិត្តតិច រាប់អានដោយវចីកម្ម ជាទីគាប់ចិត្តច្រើន មិនគាប់ចិត្តតិច រាប់អានដោយមនោកម្ម ជាទីគាប់ចិត្តច្រើន មិនគាប់ចិត្តតិច ខ្វល់ខ្វាយបម្រើ ជាទីគាប់ចិត្តច្រើន មិនគាប់ចិត្តតិច ១ ។ ម្នាលនាងសុមនា បុគ្គលណា ជាទាយក បុគ្គលនោះដល់បានបួសហើយ រមែងគ្របសង្កត់បព្វជិតឯណោះ ដែលមិនមែនជាទាយក ដោយហេតុ ៥ យ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះបើបព្វជិតទាំងពីររូបនោះ បានសម្រេចព្រះអរហត្ត បពិត្រព្រះអង្គដ៏ចម្រើន បណ្តាបព្វជិតទាំងពីររូប ដែលបានសម្រេចព្រះអរហត្តហើយនោះ តើមានសេចក្តីវិសេសស មានហេតុផ្សេងគ្នាដែរឬទេ ។ ម្នាលនាងសុមនា ត្រង់រឿងនោះ តថាគត មិនសម្តែងហេតុផ្សេងគ្នា ត្រង់ចិត្តដែលរួចស្រឡះ ដោយវិមុត្តនេះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ បពិត្រព្រះអង្គដ៏

ចម្រើន បុគ្គលគួរឲ្យទានទាំងឡាយមែន គួរធ្វើបុណ្យទាំងឡាយមែន ព្រោះថា បុណ្យទាំងឡាយ ជាឧបការៈដល់អ្នកដែលកើតជាទេវតាផង បុណ្យទាំងឡាយ ជាឧបការៈដល់អ្នកដែលកើតជាមនុស្សផង បុណ្យទាំងឡាយ ជាឧបការៈដល់អ្នកបួសផង ។ ម្នាលនាងសុមនា ហេតុនោះយ៉ាងនេះហើយ ម្នាលនាងសុមនា ហេតុនោះយ៉ាងនេះហើយ ម្នាលនាងសុមនា បុគ្គលគួរឲ្យទានទាំងឡាយ គួរធ្វើបុណ្យទាំងឡាយ ព្រោះបុណ្យទាំងឡាយ ជាឧបការៈដល់អ្នកកើតជាទេវតាផង បុណ្យទាំងឡាយ ជាឧបការៈដល់អ្នកកើតជាមនុស្សផង បុណ្យទាំងឡាយ ជាឧបការៈដល់អ្នកបួសផង ។ ព្រះដ៏មានព្រះភាគ បានត្រាស់ពាក្យនេះ លុះព្រះសុគតបានត្រាស់ពាក្យនេះហើយ ព្រះសាស្តាបានត្រាស់ពាក្យជាគាថានេះតទៅទៀតថា

យថាបិ ចន្ទោ វិមលោ　　គច្ឆំ អាកាសធាតុយា
សព្វេ តារគណេ លោកេ　　អាភាយ អតិរោចតិ
តថេវ សីលសម្បន្នោ　　សទ្ធោ បុរិសបុគ្គលោ
សព្វេ មច្ឆរិនោ លោកេ　　ចាគេន អតិរោចតិ ។

ព្រះចន្ទមិនមានមន្ទិល កាលចរទៅតាមអាកាស រមែងរុងរឿងលើស ជាងពួកផ្កាយទាំងឡាយ ឰដ៏អាកាសដោយពន្លឺ ( របស់ខ្លួន ) យ៉ាងណាមិញ បុរសបុគ្គលមានសទ្ធាបរិបូណ៌ដោយសីល រមែងរុងរឿង ជាងពួកបុគ្គលកំណាញ់ទាំងអស់ក្នុងលោកដោយចាគៈក៏យ៉ាងនោះដែរ ។

យថាបិ មេឃោ ថនយំ　　វិជ្ជុមាលី សតក្កកុ
ថលំ និន្នញ្ច បូរេតិ　　អភិវស្សំ វសុន្ធរំ

ឯវំ ទស្សនសម្បន្នោ សម្មាសម្ពុទ្ធស្សាវកោ
មច្ឆេរី អធិគណ្ហាតិ បញ្ញាឋានេហិ បណ្ឌិតោ
អាយុនា យសសា ចេវ វណ្ណេន ច សុខេន ច
ស វេ ភោគបរិព្យុឡ្ហោ បេច្ច សគ្គេ បមោទតីតិ ។

កាលមេឃ ប្រកបដោយផ្គរបន្ទោរដ៏ធ្ងៀលធ្ងាត់ បរិបូណ៌ដោយភ្នំទឹកភ្លៀងក៏បង្អុរចុះមកបំពេញផែនដី ដែលខ្ពស់ទាបឲ្យពោរពេញ យ៉ាងណាមិញ សាវ័ករបស់ព្រះសម្មាសម្ពុទ្ធដែលបរិបូណ៌ដោយទស្សនៈ ជាបណ្ឌិត រមែងគ្រប សង្កត់បុគ្គល អ្នកមានសេចក្តីកំណាញ់ ដោយហេតុ ៥ យ៉ាង គឺ អាយុ យស សម្បុរ សុខនិងអធិបតី បណ្ឌិតនោះឯង បរិបូណ៌ដោយភោគៈ ដល់ទៅលោកខាងមុខ រមែងរីករាយ ក្នុងឋានសួគ៌ ក៏យ៉ាងនោះដែរ ។

## ហេតុដែលនាងសុមនារាជកុមារី ទូលសួរបញ្ហា

ព្រះនាងសុមនារាជកុមារី ចូលគាល់ព្រះដ៏មានព្រះភាគ ព្រោះហេតុអ្វី ? ព្រោះមានបំណងទូលសួរបញ្ហា ។ បានស្តាប់មកថា ក្នុងព្រះសាសនា នៃព្រះសម្មាសម្ពុទ្ធកស្សបទសពល មានភិក្ខុពីរអង្គជាសម្លាញ់នឹងគ្នា មួយអង្គបំពេញសារាណីយធម៌ ( មានការចែកចាយនូវបច្ច័យ ៤ ដែលខ្លួនបានមកដល់បុគ្គលដែលគួរឲ្យជាដើម ) ចំណែកមួយអង្គទៀត លោកបំពេញនូវភត្តគ្គវត្ត ( បំពេញវត្តក្នុងរោងភត្ត ដោយមិនបានឲ្យទាន ) ។ ភិក្ខុដែលបំពេញនូវសារាណីយធម៌ ពោលរំលឹកភិក្ខុជាសម្លាញ់ថា អ្នកដ៏មានអាយុ ឈ្មោះថា ទានដែលមិនឲ្យផល រមែងមិនមានឡើយ កាលឲ្យរបស់ខ្លួនដល់អ្នកដទៃហើយសឹមបរិភោគទើបគួរ ។

ភិក្ខុដែលបំពេញនូវភត្តគ្គវត្ត តបថា អ្នកដ៏មានអាយុ អ្នកមិនដឹងទេឬ ការឲ្យទេយ្យធម៌ធ្លាក់ចុះ រមែងមិនគួរ បុគ្គលដែលកាន់យកត្រឹមតែអាហារញ៉ាំងជីវិតរបស់ខ្លួនឲ្យប្រព្រឹត្តទៅបានប៉ុណ្ណោះ ទើបគួរ ។ ទាំងពីរអង្គ មិនអាចញ៉ាំងគ្នាឲ្យនៅក្នុងឱវាទរបស់ខ្លួនបាន ក៏បំពេញវត្តតែរៀងខ្លួន រហូតដល់ចុតិចាកភពនោះបដិសន្ធិក្នុងទេវលោក ។ ភិក្ខុដែលបំពេញនូវសារាណីយធម៌ គ្របសង្កត់នូវភិក្ខុដែលមិនបានឲ្យទាន ដោយធម៌ ៤ យ៉ាង ក្នុងទេវលោក វិលវល់ក្នុងទេវតានិងមនុស្សអស់មួយចន្លោះព្រះពុទ្ធ ទើបកើតក្នុងក្រុងសាវត្ថី ។

អង្គដែលបំពេញនូវសារាណីយធម៌ បដិសន្ធិក្នុងគភ៌ព្រះអគ្គមហេសី នៃព្រះបាទកោសល មួយអង្គទៀត បដិសន្ធិក្នុងផ្ទៃនៃស្រីបម្រើ របស់ព្រះអគ្គមហេសីនោះ ហើយប្រសូតក្នុងថ្ងៃជាមួយគ្នា ។ ក្នុងថ្ងៃដាក់ឈ្មោះ ពោលគឺថ្វាយព្រះនាមដល់ព្រះរាជបុត្រ ព្រះមាតាស្រង់ទឹកឲ្យបុត្រហើយ ដាក់បុត្រឲ្យផ្ទំក្នុងបន្ទប់ប្រកបដោយសិរី ជាមួយនឹងបុត្ររបស់ស្ត្រីអ្នកបម្រើព្រះអគ្គមហេសីនោះឯង ។ ដោយរវល់នាំគ្នា ចាត់ចែងកិច្ចការខាងក្រៅបន្ទប់ ព្រះរាជបុត្របើកព្រះនេត្រឡើង បានឃើញស្វេតច្ឆត្រដ៏ធំផង ទីកន្លែងផ្ទំប្រកបដោយសិរី ដែលគេចាត់ចែងយ៉ាងល្អផង ព្រមទាំងព្រះរាជនិវេសន៍ ប្រដាប់ដោយគ្រឿងអលង្ការផង ទើបដឹងខ្លួនព្រះអង្គថា យើងកើតក្នុងព្រះរាជត្រកូល ។ ព្រះរាជបុត្រនឹកថា យើងធ្វើកម្មអ្វីហ្ន៎ ទើបបានកើតនៅក្នុងទីនេះដូច្នេះ ក៏រលឹកបាន ដោយផលនៃការបំពេញនូវសារាណីយធម៌ ។ ព្រះរាជបុត្រ គិតទៀតថា សម្លាញ់របស់យើងកើតក្នុងទីណាហ្ន៎ ក៏បានឃើញនៅក្នុងទីដែលទាបជាងខ្លួននោះឯង ទាំងដែលបានជ្រាបថា នេះព្រោះមកអំពីមិនជឿពាក្យរបស់យើង ទើបពោលថា សម្លាញ់ អ្នក

មិនជឿ ពាក្យរបស់យើង ។ ពេលនោះ ទារកជាសម្លាញ់ក៏តបមកវិញភ្លាមថា បើ អ៊ីចឹង តើវាយ៉ាងម៉េច ? ព្រះរាជបុត្រក៏បានឆ្លើយបញ្ជាក់ប្រាប់ទៅថា អ្នកមើល សម្បត្តិរបស់យើងមើល៍ យើងដេកនៅលើទីដ៏មានសិរី នៅក្រោមស្វេតច្ឆត្រ ចំណែកអ្នកវិញដេកនៅនឹងគ្រែទាបលើកម្រាលរឹងៗ ។ ទារកជាសម្លាញ់ពោល ថា អ្នកឯង កើតមាននូវមានះ ព្រោះអាស្រ័យរបស់ហ្នឹងឬ របស់ហ្នឹង គឺគេយក សំពត់មករុំព័ទ្ធនឹងបន្ទះឬស្សី គ្រាន់តែជាបឋវីធាតុប៉ុណ្ណោះ មិនមែនទេឬ ។

ព្រះរាជធីតាសុមនា បានស្ដាប់ពាក្យរបស់អ្នកទាំងពីរនោះហើយ ទើបគិត ថា នៅជិតៗ ប្អូនប្រុសទាំងពីរ របស់យើងមិនមានអ្នកណាឡើយ ក៏បានដើរចូល ទៅអែបនឹងមាត់ទ្វារ បានឮពាក្យថា **ធាតុ** ដូច្នេះ ក៏គិតថាពាក្យថា ធាតុនេះ មិន មាននៅខាងក្រៅ អំពីព្រះពុទ្ធសាសនាឡើយ ប្អូនប្រុសរបស់យើង ប្រាកដជា សមណទេវបុត្រ ។ ព្រះរាជធីតា បានគិតតទៅទៀតថា បើយើងនឹងក្រាបទូល ដល់ព្រះមាតាបិតាថា ទារកទាំងពីរនិយាយគ្នាយ៉ាងនេះ ព្រះបិតាជាដើមមុខតែ នឹងឲ្យគេនាំយកទៅចោល ឬយ៉ាងម៉េចៗ មិនខាន ដោយយល់ថា អ្នកទាំងពីរគឺ ជាអមនុស្ស ដូច្នេះ យើងមិនប្រាប់ហេតុការណ៍នេះដល់អ្នកណាឡើយ យើងនឹង ទូលសួរចំពោះព្រះទសពល ដែលទ្រង់ជាព្រះបិតាវិវដ្ដៈរបស់យើង ព្រះអង្គនឹង ត្រាស់ប្រាប់ សេចក្ដីនេះឲ្យយើងបានដឹងច្បាស់ ។

សោយព្រះក្រយាពេលព្រឹកស្រេចហើយ ព្រះរាជធីតា ក៏ចូលទៅគាល់ ព្រះរាជា ជាព្រះបិតា ហើយទូលសូមការអនុញ្ញាត ដើម្បីទៅគាល់ព្រះដ៏មានព្រះ ភាគ ។ ព្រះរាជាត្រាស់បង្គាប់ឲ្យចាត់រថ ៥០០ គ្រឿង ។ សូមបញ្ជាក់ថា នៅក្នុង ជម្ពូទ្វីបនេះ មានតែកុមារីបីនាក់ប៉ុណ្ណោះ ដែលបានរថ ៥០០ គ្រឿង អំពីសម្នាក់

បិតារបស់ខ្លួន គឺព្រះនាងចុន្ទី ជាព្រះរាជធីតារបស់ព្រះបាទពិម្ពិសារ ១ នាងវិសាខា ជាធីតារបស់ធនញ្ជ័យសេដ្ឋី ១ និង ព្រះនាងសុមនារាជធីតានេះឯង ១ ។ ព្រះនាងសុមនាកាន់យកគ្រឿងក្រអូប និង ផ្កាឈើហើយ បានឈរនៅក្នុងរថរបស់ខ្លួនដែលមានរថ ៥០០ ទៀតជាបរិវារ ធ្វើដំណើរចូលគាល់ព្រះបរមសាស្ដា ដោយគិតថា យើងនឹងទូលសួរព្រះអង្គនូវបញ្ហានេះ ៕